ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ក្រសួងសុខាភិបាល

និង

មជ្ឈមណ្ឌលការពារ និងត្រួតពិនិត្យជំងឺឆ្លងនៃក្រសួងសុខាភិបាលសហរដ្ឋអាមេរិក

សំរាប់

កិច្ចសហប្រតិបត្តិការក្នុងការបង្ការ និងទប់ស្កាត់ជំងឺអេដស៍ និងជំងឺឆ្លងដទៃទៀត

លេខ No. U22/CCU021772

"គំរោងគាំទ្រសកម្មភាព និងពង្រីកការបង្ការការចំលងមេរោគអេដស៍/កាមរោគ
នៅក្នុងប្រទេសកម្ពុជា"

# និយាមនៃបែបបទសំរាប់អនុវត្តសកម្មភាពរបស់គំរោង

រៀបចំដោយ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

កែសំរួល ខែសីហា ឆ្នាំ ២០០៦

# មាតិការឿង


ពាក្យបំព្រួញ (abbreviations) ........ ១
១ - សេចក្តីផ្តើម ........ ៣
១.១. គោលបំណងនៃនិយាមនៃបែបបទសំរាប់អនុវត្ត ........ ៣
១.២. គោលការណ៍ចំបង និងឯកសារយោងសំខាន់ៗ ........ ៣
២ - ការអនុម័តលើសកម្មភាព ........ ៥
៣ - ការអនុម័តលើថវិកា និង ការផ្តល់ថវិកា ........ ៦
៣.១. គណនីនៅធនាគារ ........ ៦
៣.២. ការបើកប្រាក់ចំនួន $250,000.00 និងលើសពីនេះ ........ ៦
៣.៣. ការបើកប្រាក់តិចជាង $250,000.00 ........ ៦
៣.៤. ការរក្សាទុកប្រាក់បន្ទាប់បន្សំ (Petty cash) ........ ៧
៣.៥. ការបើកប្រាក់បុរេប្រទាន (Advances) ........ ៩
៣.៦. ការបើកប្រាក់បុរេប្រទានសំរាប់វគ្គបណ្តុះបណ្តាល ឬសកម្មភាពផ្សេងៗ ........ ១០
៣.៧. ការបំពេញទឹកប្រាក់បន្ថែម ........ ១០
៣.៨. ការធ្វើសាវនកម្ម (Audits) ........ ១០
៤ - កាលវិភាគនៃការតាមដាន ការចុះអភិបាល និង ការធ្វើរបាយការណ៍ ........ ១០
៥ - និតិវិធីនៃការធ្វើលទ្ធកម្ម និង កំរិតទឹកប្រាក់អប្បបរិមា (CEILINGS) ........ ១១
៥.១. ការធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ ........ ១១
៥.១.១. ការអនុម័តតាមកំរិតទឹកប្រាក់អប្បបរិមា ........ ១១
៥.១.២. អចនវត្ថុ និង ការចុះបញ្ជីសារពើភ័ណ្ឌ ........ ១២
៥.២. ការធ្វើលទ្ធកម្មលើសេវាកម្ម : បុគ្គល ក្រុមហ៊ុន ........ ១៣
៥.២.១. ឯកសារយោងសំខាន់ៗ ........ ១៣
៥.២.២. ទីប្រឹក្សាជាបុគ្គល ........ ១៣
៥.២.៣. ការផ្តល់ប្រឹក្សាដោយក្រុមហ៊ុន ........ ១៥
៥.៣. ការធ្វើលទ្ធកម្មលើការងារសំណង់ ........ ១៦
៥.៤. ការវាយតំលៃលើការងារលទ្ធកម្ម ........ ១៨
៥.៥ ការធានារ៉ាប់រង ........ ១៨

៦ - ការកំណត់អត្រាប្រាក់ឧបត្ថម្ភសំរាប់ធ្វើដំណើរក្នុងប្រទេស ការចុះអភិបាល និង ប្រាក់សំរាប់លើកទឹកចិត្តក្នុង
ការអនុវត្តន៏ការងារ ........ ១៨
៧ - សោហ៊ុយសំរាប់ការធ្វើដំណើរក្រៅប្រទេស ........ ២០

## បញ្ជីតារាង

តារាងទី ១ : សង្ខេបពីដំណើរការនៃការអនុវត្តន៏សកម្មភាព ៤
តារាងទី ២ : សង្ខេបពីយន្តការនៃការអនុម័ត ៦
តារាងទី ៣ : ការកំណត់លើការរក្សាទុកប្រាក់បន្ទាប់បន្សំ ៨
តារាងទី ៤ : សង្ខេបលើការអនុម័តថវិកា ៩
តារាងទី ៥ : សង្ខេបលើការងាររៀបចំរបាយការណ៍ ១១
តារាងទី ៦ : កំរិតទឹកប្រាក់អប្បបរិមាសំរាប់ធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ ១២
តារាងទី ៧ : សង្ខេបអំពីដំណើរការជ្រើសរើសទីប្រឹក្សាជាបុគ្គល ១៣
តារាងទី ៨ : សង្ខេបអំពីដំណើរការជ្រើសរើសទីប្រឹក្សាមកពីក្រុមហ៊ុន ១៥
តារាងទី ៩ : សង្ខេបអំពីដំណាក់កាលនៃការធ្វើលទ្ធកម្មលើការងារជួសជុលខ្នាតតូច ១៧
តារាងទី ១០ : ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសំរាប់មន្ត្រីរដ្ឋាភិបាល ក្នុងការធ្វើចុះបំពេញបេសកម្មក្នុងប្រទេស ១៨
តារាងទី ១១ : ប្រាក់ឧបត្ថម្ភ សិក្ខាកាមចូលរួមក្នុងការបណ្តុះបណ្តាល ឬ សិក្ខាសាលា ១៨
តារាងទី ១២ : អត្រាប្រាក់ឧបត្ថម្ភនៅពេលបំពេញការងារ ១៩

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ : សេចក្តីសង្ខេបអំពីដំណើរការនៃការធ្វើលទ្ធកម្ម ២១
ឧបសម្ព័ន្ធទី ៣ : ឯកសារគំរូសំរាប់ធ្វើលទ្ធកម្មលើសំណង់ខ្នាតតូច ៣២
ឧបសម្ព័ន្ធទី ៤ : ផែនការសកម្មភាព ( ឯកសារភ្ជាប់ទី ១)
ឧបសម្ព័ន្ធទី ៥ : ផែនការលទ្ធកម្ម ( ឯកសារភ្ជាប់ទី ២)
ឧបសម្ព័ន្ធទី ៦ : គំរូលិខិតស្នើសុំបំពេញប្រាក់បន្ថែម(Replenishment) ( ឯកសារភ្ជាប់ទី ៣) ៣៧
ឧបសម្ព័ន្ធទី ៧ : របាយការណ៍ហិរញ្ញវត្ថុ ( ឯកសារភ្ជាប់ទី ៤)
ឧបសម្ព័ន្ធទី ៨ : របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ( ឯកសារភ្ជាប់ទី ៥)

## ពាក្យបំព្រួញ (abbreviations)

| | |
|---|---|
| APW | Agreement to Perform Work |
| BCC | Behavior Change Communication |
| CWO | Cash Order |
| DFID | Department for International Development |
| HAMT | HIV/AIDS Management team |
| HIV/AIDS | Human- |
| ICB | International Competitive Bidding |
| LoA | Letter of Agreement |
| MoH | Ministry of Health |
| MTO | Money Transfer Order |
| NCHADS | National Centre for HIV/AIDS, Dermatology and STD |
| NGO | Non Governmental Organization |
| OD | Operational District |
| OI/ART | Opportunistic Infection/Anti-retroviral Therapy |
| PAO | Provincial AIDS Office |
| PBSI | Performance- based Salary Incentives |
| PHD | Provincial Health Department |
| QA | Quality Assurance |
| RGC | Royal Government of Cambodia |
| SoE | Statement of Expenditure |
| SOP | Standard Operating Procedures |
| STD | Sexually Transmitted Disease |
| STI | Sexually Transmitted Infection |
| TB | Technical Bureau |
| UN | United Nations |
| VCCT | Voluntary Confidential Counseling and Testing |

## មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

## *"គំរោងគាំទ្រសកម្មភាព និងពង្រីកការបង្ការការចំលងមេរោគអេដស៍/កាមរោគ នៅក្នុងប្រទេសកម្ពុជា"*

## និយាមនៃបែបបទសំរាប់អនុវត្ត សំរាប់អនុវត្តសកម្មភាពរបស់គំរោង

### ១ ~ សេចក្តីផ្តើម

### ១.១. គោលបំណងនៃនិយាមនៃបែបបទសំរាប់អនុវត្ត

សកម្មភាពដែលបានឧបត្ថម្ភគាំទ្រថវិកាពីប្រភពផ្សេងៗ គ្រប់គ្រងដោយមជ្ឈមណ្ឌជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល និងជាផ្នែកមួយនៃកម្មវិធីជាតិ ។ ក្នុងគោលបំណងធានាថា គំរោងអាចសំរេចបាននូវគោលដៅ និងគោលបំណងប្រកបដោយ តម្លាភាព និងការទទួលខុសត្រូវ វាចាំបាច់ ណាស់ក្នុងការធានាថា ការសំរេចចិត្តធ្វើឡើងអោយបានទាន់ពេល ការអនុវត្តន៍សកម្មភាពប្រកបដោយប្រសិទ្ធិភាពខ្ពស់ ការផ្តល់ថវិកាត្រូវស៊ីសង្វាក់គ្នាទៅនឹងផែនការផ្តល់ថវិការបស់កម្មវិធី និងការធ្វើលទ្ធកម្មត្រូវ បានតាមដានប្រកបដោយប្រសិទ្ធិភាព ។
ដោយសារតែភាពស្មុគ្រស្មាញ និងវិសាលភាពនៃកម្មវិធីរបស់មជ្ឈមណ្ឌលជាតិ និងប្រភពថវិកាផ្សេងៗគ្នាដែលផ្គត់ផ្គង់ដល់មជ្ឈមណ្ឌលជាតិ វាទាមទារអោយមានភាពច្បាស់លាស់ តម្លាភាព ភាពស្តង់ដាប្រព័ន្ធក្នុងការ សំរេចចិត្ត និង អនុម័តលើការអនុវត្តន៍គំរោង ការបែងចែកថវិកា និង ការតាមដាន និងការធ្វើរបាយការណ៍ដោយទៀងទាត់ ។

គោលបំណងរបស់និយាមនៃបែបបទសំរាប់អនុវត្ត គឺដើម្បីកំណត់ :

- យន្តការក្នុងការអនុម័តលើសកម្មភាពដែលមានក្នុងគំរោង
- គំរូក្នុងការគ្រប់គ្រងថវិកា ដែលគូសបញ្ជាក់ពីដំណើរការលើការអនុម័ត និង ការកំណត់ចំនួនថវិកាដែលត្រូវផ្តល់ជូនតាមរយៈ មូលប្បទានប័ត្រ ឬ តាម money transfer order (MTO) និង ការរក្សាទុកប្រាក់បន្ទាប់បន្សំ
- កម្មវិធីតាមដាន និង ការផ្ញើរបាយការណ៍
- គំរូនូវដំណើរការធ្វើលទ្ធកម្មលើសំភារៈ/បរិក្ខា សេវាកម្ម និង ការសាងសង់
- ក៏រិតប្រាក់ឧបត្ថម្ភដែលបានអនុញ្ញាតអំពីថ្លៃធ្វើដំណើរ ការផ្តល់ប្រាក់ឧបត្ថម្ភ និងការចុះអភិបាលការងារ
- យន្តការ និង ដំណើរការ ក្នុងការធ្វើវិមជ្ឈការ ដល់ថ្នាក់ខេត្ត /ក្រុង

### ១.២. គោលការណ៍ចំបង និងឯកសារយោងសំខាន់ៗ

កំណត់សំគាល់នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការផ្តល់ជំនួយ លេខ #U22/CCU0121772 ។

គោលការណ៍ចំបងសំរាប់ការអនុម័ត ការគ្រប់គ្រង ការធ្វើលទ្ធកម្ម ការផ្តល់ថវិកា បែបបទគណនេយ្យ និងការធ្វើសាវនកម្ម គឺ ផ្អែកតាមនិយាមនៃបែបបទសំរាប់អនុវត្តរបស់ក្រសួងសុខាភិបាល, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ថវិកាផ្តល់អោយដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក (World Bank) បំពេញបន្ថែមដោយបទពិសោធន៍របស់មជ្ឈមណ្ឌលជាតិដែលបានអនុវត្តគំរោងឧបត្ថម្ភដោយ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការសុខភាពពិភពលោក, Department For International Development (DFID), UK និងភ្នាក់ងារផ្តល់ជំនួយផ្សេងទៀត។

**តារាងទី ១ : សង្ខេបពីដំណើរការនៃការអនុវត្តន៍សកម្មភាព**

| ជំហាន | សកម្មភាព | ប្រភព | អនុម័តដោយ |
|---|---|---|---|
| **ផែនការ** | | | |
| ១ | រៀបចំគំរោងផែនការសកម្មភាពប្រចាំឆ្នាំ | ថវិការបស់កិច្ចព្រមព្រៀងសហប្រតិបត្តិការប្រចាំឆ្នាំដែលបាន អនុម័តដោយ CDC សំរាប់ផ្នែកនិមួយៗរបស់គំរោង | ប្រធានមជ្ឈមណ្ឌលជាតិ |
| ២ | រៀបចំគំរោងផែនការសកម្មភាពសំរាប់រយៈពេល ៦ខែ | ផែនការសកម្មភាពប្រចាំឆ្នាំដែលបានអនុម័ត | ប្រធានមជ្ឈមណ្ឌលជាតិ |
| **ការទទួលថវិកា** | | | |
| ១ | ការបង្វែរថវិកាពី CDC មកគណនីរបស់មជ្ឈមណ្ឌលជាតិ | កិច្ចព្រមព្រៀងសហប្រតិបត្តិការ | ប្រធានមជ្ឈមណ្ឌលជាតិ |
| **ការបើកថវិកា *(disbursement)*** | | | |
| ១ | **មជ្ឈមណ្ឌលជាតិ :** ការបើកថវិកាពីគណនី | និយាមនៃបែបបទសំរាប់អនុវត្ត | ប្រធានមជ្ឈមណ្ឌលជាតិ |
| ២ | **Sub components :** ទទួលថវិកាពីមជ្ឈមណ្ឌលជាតិ និងដកថវិកាពីគណនីរបស់ខ្លួន | និយាមនៃបែបបទសំរាប់អនុវត្ត | ប្រធាន Sub component និមួយ (NIPH, PST, BTB, BMC, NAA, NMCH) |
| **ការងារគណនេយ្យ** | | | |
| ១ | ការធានាគណនី | ការចុះបញ្ជីចំណាយ និងឯកសារអមផ្សេងៗ | ប្រធានមជ្ឈមណ្ឌលជាតិ, ប្រធាន Sub component និមួយ (NIPH, PST, BTB, BMC, NAA, NMCH) |

| | | | |
|---|---|---|---|
| ២ | ផ្ញើរបាយការណ៏ចំណាយប្រចាំខែ | របាយការណ៏ចំណាយ និងឯកសារអមផ្សេងៗ | ប្រធានមជ្ឈមណ្ឌលជាតិ, ប្រធាន Sub component និមួយ (NIPH, PST, BTB, BMC, NAA, NMCH) |
| ៣ | មជ្ឈមណ្ឌលជាតិរៀបចំរបាយការណ៏រួម | របាយការណ៏ចំណាយប្រចាំខែ | ប្រធានមជ្ឈមណ្ឌលជាតិ |
| **របាយការណ៏** | | | |
| ១ | របាយការណ៏បច្ចេកទេសប្រចាំឆមាស | កាលកំណត់ និងលក្ខខ័ណ្ឌក្នុងកិច្ចព្រមព្រៀង និងការសំរេចបានក្នុងរយៈពេល ៦ខែ | ប្រធានមជ្ឈមណ្ឌលជាតិ, ប្រធាន Sub component និមួយ (NIPH, PST, BTB, BMC, NAA, NMCH) |
| ២ | មជ្ឈមណ្ឌលជាតិរៀបចំរបាយការណ៏រួម | របាយការណ៏បច្ចេកទេសរៀងរាល់ ៦ខែ របស់ Sub component | ប្រធានមជ្ឈមណ្ឌលជាតិ |

របាយការណ៏សកម្មភាពរួមចុងក្រោយ (Final Progress Report) គប្បីរៀបរាប់សង្ខេបពីសកម្មភាពរួមរបស់គំរោងទាំងមូល (៥ ឆ្នាំ) ។ របាយការណ៏នេះគប្បីផ្ញើទៅ CDC Atlanta នៅដំណាច់ខែតុលា ឆ្នាំ ២០០៧ ក្នុងកំឡុងពេល ៩០ ថ្ងៃ បន្ទាប់ពីគំរោងត្រូវបានបញ្ចប់ ។

## ២ ~ ការអនុម័តលើសកម្មភាព

មុននឹងចាប់ផ្តើមប្រើប្រាស់ថវិកាសំរាប់រយៈពេលនិមួយៗ, គ្រប់ Sub-components ត្រូវដាក់ជូនមជ្ឈមណ្ឌលជាតិនូវគំរោងផែនការសកម្មភាពលំអិតប្រចាំឆ្នាំដើម្បីពិនិត្យ និងឯកភាព (ឧបសម្ព័ន្ធទី ៤) ។ មជ្ឈមណ្ឌលជាតិនឹងធ្វើលិខិតឯកភាពលើគំរោងផែនការសកម្មភាពលំអិតទាំងនេះ ។ ការឯកភាពលើនេះនឹងឯកភាពលើរាល់សកម្មភាពទាំងអស់របស់ផែនការ ។ ការអនុម័តបន្ថែមទៀតនឹងតំរូវអោយមានប្រសិនបើមានការផ្លាស់ប្តូរសំខាន់នៅក្នុងផែនការសកម្មភាពលំអិត ឬ ថវិកា ។ ផែនការសកម្មភាពលំអិតទាំងនេះ នឹងរួមបញ្ចូលនូវសេចក្តីសង្ខេបអំពីផែនការបែងចែកថវិកាទៅចំណាត់ថ្នាក់ និងគំរោងផែនការលទ្ធកម្មសំរាប់រយៈពេលនៃការផ្តល់ថវិកា (ឧបសម្ព័ន្ធ ៥) ។ ផែនការទាំង ៣ នេះ (សកម្មភាព បែងចែកថវិកា និងលទ្ធកម្ម) នឹងត្រូវបញ្ជូនមកមជ្ឈមណ្ឌលជាតិដើម្បីពិនិត្យ និងសំរេច និងចំលងជូនការិយាល័យ US CDC ប្រចាំនៅកម្ពុជា ។

សកម្មភាពទាំងឡាយណាដែលមិនបានដាក់បញ្ចូលក្នុងគំរោងផែនការសកម្មភាពប្រចាំឆ្នាំ និង ប្រចាំឆមាសត្រូវផ្ញើមកមជ្ឈមណ្ឌលជាតិដាច់ដោយឡែក និងត្រូវពិនិត្យ និងឯកភាព ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៏ សើស្បែក និងកាមរោគ និងការិយាល័យ US CDC ប្រចាំនៅកម្ពុជា ។

**តារាងទី ២ : សង្ខេបពីយន្តការនៃការអនុម័ត**

| ផែនការ | រៀបចំដោយ | អនុម័តដោយ | ផ្តល់ពត៌មានជូន |
|---|---|---|---|
| ផែនការប្រចាំឆ្នាំ | មជ្ឈមណ្ឌលជាតិ, វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ខេត្ត ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | ប្រធាន មជ្ឈមណ្ឌលជាតិ | ការិយាល័យ US CDC ប្រចាំនៅកម្ពុជា |
| ផែនការប្រចាំឆមាស | មជ្ឈមណ្ឌលជាតិ, វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ខេត្ត ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | ប្រធាន មជ្ឈមណ្ឌលជាតិ | ការិយាល័យ US CDC ប្រចាំនៅកម្ពុជា |

## ៣ ៖ ការអនុម័តលើថវិកា និង ការផ្តល់ថវិកា

### ៣.១. គណនីនៅធនាគារ

Sub-component និមួយៗ ត្រូវរក្សាទុកថវិការបស់គំរោងនៅក្នុងគណនីមួយដាច់ដោយឡែក ។ គណនីសំរាប់គំរោងគប្បីបើកនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ឬ ធនាគារជាតិនៃកម្ពុជា ឬ ធនាគារអេស៊ីលីដា (ACLEDA) សំរាប់ខេត្តពោធិសាត់ បាត់ដំបង និង បន្ទាយមានជ័យ ។

### ៣.២. ការបើកប្រាក់ចំនួន $25,000.00 និងលើសពីនេះ

ការបើកប្រាក់ (សំរាប់ប្រតិបត្តិការ) ដែលមានចំនួនទឹកប្រាក់ $25,000.00 ឬលើសពីនេះសំរាប់គ្រប់ថ្នាក់ចំណាយទាំងអស់របស់គំរោង តំរូវអោយការឯកភាពពីប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (ចូលរួមវាយតំលៃការដេញថ្លៃ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការ ដោយតំណាងការិយាល័យ US-CDC ប្រចាំនៅកម្ពុជា) ។

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងមានសិទ្ធិចុះហត្ថលេខាលើមូលប្បទានប័ត្រសំរាប់ចំនួនទឹកប្រាក់ $25,000.00 និងលើសពីនេះ ។

### ៣.៣. ការបើកប្រាក់តិចជាង $25,000.00

ការបើកប្រាក់តិចជាង $25,000.00 តំរូវមានការអនុម័តពីប្រធានមជ្ឈមណ្ឌលជាតិ ។

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងមានសិទ្ធិចុះហត្ថលេខាលើមូលប្បទានប័ត្រសំរាប់ចំនួនទឹកប្រាក់តិចជាង $25,000.00 ។ អនុប្រធានមជ្ឈមណ្ឌលជាតិនឹងមានសិទ្ធិចុះហត្ថលេខាលើមូលប្បទានប័ត្រសំរាប់ទឹកប្រាក់តិចជាង $500.00 នៅពេលដែលប្រធានមជ្ឈមណ្ឌលមានបេសកកម្ម ឬ អវត្តមាន ។ ហត្ថលេខានេះតំរូវអោយមានការឯកភាពពីប្រធាន ។

ប្រធានវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ មន្ទីរសុខាភិបាលខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលគាំពារមាតា និងទារក មានសិទ្ធិចុះហត្ថលេខាលើមូលប្បទានប័ត្រសំរាប់ទឹកប្រាក់តិចជាង $10,000.00 ។

ការស្នើសុំអនុម័តដោយប្រធានមជ្ឈមណ្ឌលជាតិ ប្រធានវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ មន្ទីរសុខាភិបាលខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលគាំពារមាតា និងទារក ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

- ការមានថវិកានៅក្នុងគណនី
- ការចំណាយសមស្របនឹងថវិកាដែលបានលើកនៅក្នុងផែនការ
- តម្លាភាពដោយការពិគ្រោះយោបល់គ្នា
- ការបើកថវិកាគោរពតាមគោលការណ៍ និង
- មានឯកសារអមគ្រប់គ្រាន់សំរាប់ការធ្វើសាវនកម្ម

រាល់ការបើកប្រាក់ទាំងអស់ នៅគ្រប់កំរិតថវិកា (thresholds) នឹងត្រូវតាមដានប្រចាំខែ ហើយ របាយការណ៍ស្ថានភាពថវិការបស់គំរោង (FSR) (ឧបសម្ព័ន្ធទី ៨) នឹងត្រូវផ្ញើទៅ CDC Atlanta ជាប្រចាំឆ្នាំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។ គោលបំណងរបស់ការតាមដានរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ត្រូវដាក់បញ្ចូលរបាយការណ៍ចំណាយស្របទៅតាមរបាយការណ៍ចំណាយសង្ខេប និង តារាងតុល្យភាពថវិកា (ឧបសម្ព័ន្ធទី ៧) ។

### ៣.៤. ការរក្សាទុកប្រាក់បន្ទាប់បន្សំ (Petty cash)

ការបើកថវិកាជាសាច់ប្រាក់ មានការលំបាកក្នុងការគ្រប់គ្រង ជាពិសេសនៅក្នុងករណីមានការចំណាយ និង ការស្នើសុំថវិកាមានចំនួនច្រើន ។ ដើម្បីអោយមានភាពងាយស្រួលធ្វើការផ្ទៀងផ្ទាត់នៅពេលធ្វើសាវនកម្ម ប័ណ្ណចំណាយ (disbursement vouchers) ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ។ ដូច្នេះ ការបើកប្រាក់បន្ទាប់បន្សំត្រូវធ្វើឡើងដោយប្រើប័ណ្ណចំណាយ នៅក្នុងគ្រប់ករណីដែលអាចធ្វើទៅបាន ។ នៅករណីដែលមានការប្រើប្រាស់ប្រាក់បន្ទាប់បន្សំត្រូវបានគេអនុវត្តជាទូទៅនោះ ការកំរិតចំនួនថវិកាតំរូវឱ្យមាន ដូចក្នុងតារាងខាងក្រោមនេះ :

**តារាងទី ៣ : ការកំណត់លើការរក្សាទុកប្រាក់បន្ទាប់បន្សំ**

**កំរិតប្រាក់បន្ទាប់បន្សំ**

| | |
|---|---|
| វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ មន្ទីរសុខាភិបាលខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ | $5,000 |
| មជ្ឈមណ្ឌលជាតិ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង មជ្ឈមណ្ឌលគាំពារមាតា និងទារក | $1,000 |

***ការចំណាយអតិបរមាសំរាប់ប្រតិបត្តិការមួយ***

| | |
|---|---|
| មន្ទីរសុខាភិបាលខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ | $2,500.00 |
| មជ្ឈមណ្ឌលជាតិ, វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង មជ្ឈមណ្ឌលគាំពារមាតា និងទារក | $500.00 |

- ចំនួនអតិបរមាដែលអាចបើកប្រាក់រក្សាទុកបន្ទាប់បន្សំរបស់មជ្ឈមណ្ឌលជាតិ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលគាំពារមាតា និងទារក សំរាប់ប្រតិបត្តិការមួយ គឺមានចំនួន $500.00 ។ រាល់សំណើសុំត្រូវធ្វើឡើងមន្ត្រីបច្ចេកទេស ឬគណនេយ្យកររបស់គំរោង ហើយមានការឯកភាពពីប្រធាន ឬអនុប្រធានអង្គភាព ។ រាល់ការចំណាយនឹងត្រូវត្រួតពិនិត្យមុននឹងធ្វើការបំពេញទឹកប្រាក់វិញ យ៉ាងហោច ១ខែ ម្តង ដោយប្រធាន ឬ អនុប្រធានអង្គភាព ។
- ចំនួនអតិបរមាដែលអាចបើកប្រាក់រក្សាទុកបន្ទាប់បន្សំរបស់មន្ទីរសុខាភិបាលខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សំរាប់ប្រតិបត្តិការមួយ គឺ $2,500.00 ។ រាល់សំណើសុំត្រូវធ្វើឡើងមន្ត្រីបច្ចេកទេស ឬគណនេយ្យកររបស់គំរោង ហើយមានការឯកភាពពីប្រធានមន្ទីរសុខាភិបាល ។ រាល់ការចំណាយនឹងត្រូវត្រួតពិនិត្យមុននឹងធ្វើការបំពេញទឹកប្រាក់វិញ យ៉ាងហោច ១ខែ ម្តង ដោយប្រធានមន្ទីរសុខាភិបាល ។

គោលបំណងនៃការតាមដាន គណនេយ្យកររបស់គំរោង និង Sub-components ត្រូវទទួលខុសត្រូវក្នុងការធានាថា រាល់គណនីនៅធនាគារ និង គណនីរក្សាទុកប្រាក់បន្ទាប់បន្សំ នឹងត្រូវធ្វើការផ្ទៀងផ្ទាត់ (Reconcile) ប្រចាំខែ ។ ការចំណាយប្រាក់បន្ទាប់បន្សំ ត្រូវដាក់ភ្ជាប់មកជាមួយនូវឯកសារស្នើសុំថវិកាបំពេញបន្ថែមចុងក្រោយ និង ឯកសារស្នើសុំបំពេញបន្ថែមថ្មី ។

**តារាងទី ៤ : សង្ខេបលើការអនុម័តថវិកា**

| កំណត់ថវិកា Threshold (US$) | សិទ្ធិក្នុងការអនុម័ត | សិទ្ធិក្នុងការចុះហត្ថលេខា | ស្នើដោយ |
|---|---|---|---|
| ≥25,000.00 | ប្រធានមជ្ឈមណ្ឌលជាតិ | ប្រធានមជ្ឈមណ្ឌលជាតិ | ផ្នែកជំនាញនានានៃមជ្ឈមណ្ឌលជាតិ ឬប្រធាន/ប្រធានមន្ទីរសុខាភិបាលខេត្ត |
| <25,000.00 | ប្រធានមជ្ឈមណ្ឌលជាតិ | ប្រធានមជ្ឈមណ្ឌលជាតិ | ផ្នែកជំនាញនានានៃមជ្ឈមណ្ឌលជាតិ ឬប្រធាន/ប្រធានមន្ទីរសុខាភិបាលខេត្ត |
| <10,000.00 | ប្រធានមជ្ឈមណ្ឌលជាតិ ឬ ប្រធាន Sub-component និមួយៗ | ប្រធានមជ្ឈមណ្ឌលជាតិ ឬ ប្រធាន Sub-component និមួយៗ | ផ្នែកជំនាញនានានៃមជ្ឈមណ្ឌលជាតិ / គណនេយ្យកររបស់ Sub-component និមួយៗ |
| <500.00 | ប្រធាន ឬ អនុប្រធានមជ្ឈមណ្ឌលជាតិ ឬ ប្រធាន Sub-component និមួយៗ | ប្រធានមជ្ឈមណ្ឌលជាតិ ឬ ប្រធាន Sub-component និមួយៗ | ផ្នែកជំនាញនានានៃមជ្ឈមណ្ឌលជាតិ / គណនេយ្យកររបស់ Sub-component និមួយៗ |

**៣.៥. ការបើកប្រាក់បុរេប្រទាន (Advances)**

ការបើកប្រាក់បុរេប្រទានសំរាប់អនុវត្តសកម្មភាពរបស់កម្មវិធីទៅអោយ Sub-component និមួយៗ ត្រូវផ្អែកទៅលើនិតិវិធីរបស់គំរោង ។ ក៏រឹតថវិកាសំរាប់បើកបុរេប្រទាននឹងប្រមូលត្រឡប់មកវិញនៅក្នុងរយៈពេល ៣ ខែ មុនគំរោងត្រូវបានបញ្ចប់ ។

ចំនួនអតិបរមាក្នុងការបើកប្រាក់បុរេប្រទានសំរាប់អនុវត្តសកម្មភាពត្រូវកំណត់ដូចខាងក្រោម :

- ❖ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ = US$15,000.00
- ❖ មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ = US$15,000.00
- ❖ មន្ទីរសុខាភិបាលខេត្តពោធិសាត់ = US$7,000.00

- ❖ មន្ទីរសុខាភិបាលខេត្តបាត់ដំបង = US$7,000.00
- ❖ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ = US$10,000.00
- ❖ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក = US$10,000.00

### ៣.៦. ការបើកប្រាក់បុរេប្រទានសំរាប់វគ្គបណ្តុះបណ្តាល ឬសកម្មភាពផ្សេងៗ

ការបើកប្រាក់បុរេប្រទានសំរាប់រៀបចំវគ្គបណ្តុះបណ្តាល ឬសកម្មភាពផ្សេងៗ នឹងត្រូវធ្វើការទូទាត់សងវិញមិនអោយលើសពី ៦០ ថ្ងៃ បន្ទាប់ពីសកម្មភាពនិមួយៗបានបញ្ចប់ ។

### ៣.៧. ការបំពេញទឹកប្រាក់បន្ថែម

នៅដំណាច់ខែនិមួយៗ ឬនៅពេលដែលសមតុល្យប្រាក់បុរេប្រទានលើកដំបូងនៅសល់តិចជាង ៥០% មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ពោធិសាត់ បាត់ដំបង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក នឹងដាក់ជូនមជ្ឈមណ្ឌលជាតិនូវរបាយការណ៍ចំណាយ (Statement of Expendidutre) និងឯកសារអមផ្សេងៗ ដើម្បីបញ្ជាក់អំពីការចំណាយដែលបានកើតឡើង (ឧបសម្ព័ន្ធទី ៦) លើកលែងតែវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈដែលត្រូវរក្សាឯកសារអមផ្សេងៗទុកដោយខ្លួនសំរាប់ធ្វើសវនកម្ម ។ មជ្ឈមណ្ឌលជាតិនឹងពិនិត្យមើល និងបំពេញទឹកប្រាក់បន្ថែមជូន ។

### ៣.៨. ការធ្វើសាវនកម្ម (Audits)

ដើម្បីធានាឱ្យមាននូវតម្លាភាព ការទទួលខុសត្រូវ និងស្របតាមលក្ខខ័ណ្ឌបានចែងក្នុងកិច្ចព្រមព្រៀងសហប្រតិបត្តិការរបស់គំរោង គណនីរបស់គំរោងនឹងត្រូវធ្វើសាវកម្មជារៀងរាល់ឆ្នាំ ដោយក្រុមអ្នកធ្វើសាវនកម្មឯករាជ្យមកពីខាងក្រៅដែលមានបទពិសោធន៍នៅសហរដ្ឋអាមេរិក ។ របាយការណ៍សវនកម្មតំរូវអោយដាក់ជូន CDC Atlanta ដើម្បីពិនិត្យមិនអោយលើសពី ៩០ ថ្ងៃ បន្ទាប់រយៈពេលផ្តល់ថវិកាត្រូវបានបញ្ចប់ ។

## ៤ ៊ កាលវិភាគនៃការតាមដាន ការចុះអភិបាល និង ការធ្វើរបាយការណ៍

របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ និងរបាយការណ៍សកម្មភាពប្រចាំឆមាស គឺត្រូវរៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ពោធិសាត់ បាត់ដំបង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងដាក់ជូនប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីពិនិត្យ និងចំលងជូនការិយាល័យ CDC ប្រចាំនៅកម្ពុជា ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ទទួលបន្ទុកក្នុងប្រមូលចងក្រងរាល់របាយការណ៍សកម្មភាពទាំងអស់ដែលធ្វើឡើងដោយអ្នកទទួលជំនួយបន្ត និង ផ្ញើរបាយការណ៍ទាំងនោះទៅ CDC Atlanta មិនអោយលើស ៣០ ថ្ងៃ បន្ទាប់ពីរយៈពេល ១ឆមាស ត្រូវបានបញ្ចប់ ។

**តារាងទី ៥ ៖ សង្ខេបលើការងាររៀបចំរបាយការណ៍**

| របាយការណ៍ | ប្រភេទ | រៀបចំដោយ | ដាក់ជូន | បញ្ជូនទៅ |
|---|---|---|---|---|
| ប្រចាំខែ | ហិរញ្ញវត្ថុ | NCHADS/NIPH/BMC/ PST/BTB/NAA/NMCHC | ប្រធានមជ្ឈមណ្ឌលជាតិ | |
| ប្រចាំឆមាស | សកម្មភាព | NCHADS/NIPH/BMC/ PST/BTB/NAA/NMCHC | ប្រធានមជ្ឈមណ្ឌលជាតិ | CDC Cambodia & Atlanta |
| ប្រចាំឆ្នាំ | ហិរញ្ញវត្ថុ | NCHADS | CDC Atlanta | CDC Cambodia & Atlanta |

## ៥ ~ និតិវិធីនៃការធ្វើលទ្ធកម្ម និង កំរិតទឹកប្រាក់អប្បបរិមា (CEILINGS)

គ្រប់ការធ្វើលទ្ធកម្មទាំងអស់នឹងត្រូវធ្វើឡើងដោយយោងតាមនិតិវិធីគំរូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ។

### ៥.១. ការធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ

រាល់ការធ្វើលទ្ធកម្មទាំងអស់ដោយប្រើប្រាស់ថវិការបស់កិច្ចព្រមព្រៀង នឹងត្រូវធ្វើឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ លើកលែងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈដែលទទួលខុសត្រូវក្នុងការធ្វើលទ្ធកម្មដោយខ្លួនឯង ។ គ្រប់ Sub-component ទាំងអស់ត្រូវបានអនុញ្ញាតអោយប្រើប្រាស់និតិវិធីទិញធម្មតា (ការទិញដែលតំលៃតិចជាង US$400.00) ។ មន្ត្រីលទ្ធកម្មរបស់គំរោងនៃមជ្ឈមណ្ឌលជាតិ ឬវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ នឹងទទួលខុសត្រូវក្នុងការធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ សេវាកម្មផ្សេងៗ ដោយយោងតាមគំរោងផែនការលទ្ធកម្មរបស់ Sub-components ។

#### ៥.១.១. ការអនុម័តតាមកំរិតទឹកប្រាក់អប្បបរិមា

ចំពោះវត្ថុដែលមានតំលៃតិចជាង $400 ការទិញផ្ទាល់ដោយមិនចាំបាច់មានសំណើតំលៃ (quotations) ។

ចំពោះវត្ថុដែលមានតំលៃចាប់ពី $400 ទៅ $80,000 ត្រូវអនុវត្តតាមនិតិវិធីទិញដោយផ្ទាល់ ៖ តំរូវឱ្យមាន សំណើស្នង់តំលៃចំនួន ៣ ដោយគោរពតាមគោលការណ៍ណែនាំ និង លិខិតស្នើសុំឱ្យដាក់តំលៃ ការវាយតំលៃលើ quotations ការចុះកិច្ចសន្យា។ល។ (ឧបសម្ព័ន្ធទី ១ ៖ សង្ខេបអំពីដំណើការនៃការធ្វើលទ្ធកម្ម និងគំរូធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ) ។

ចំពោះវត្ថុដែលមានតំលៃចាប់ពី $80,000 ទៅ $100,000 ត្រូវអនុវត្តតាមនិតិវិធីដេញថ្លៃកំរិតជាតិ (National Competitive Bidding) ។ ចំពោះវត្ថុដែលមានតំលៃលើពី $100,000 ត្រូវអនុវត្តតាមនិតិវិធីដេញថ្លៃកំរិតអន្តរជាតិ (International Competitive Bidding) ។

ការដេញថ្លៃកំរិតជាតិ និងអន្តរជាតិ នឹងត្រូវគោរពតាមគោលការណ៍ណែនាំជាស្តង់ដារសំរាប់ធ្វើលទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់គំរោងដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ។

ចំពោះសំភារៈបរិក្ខារដែលមានតំលៃតិចជាង US$25,000.00 ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អាចធ្វើការឯកភាព ។ ចំពោះសំភារៈបរិក្ខារដែលមានតំលៃ US$25,000.00 ឬលើសពីនេះ ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អាចធ្វើការឯកភាព និងមានតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជាចូលរួមក្នុងការវាយតំលៃលើសំណើតំលៃ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ។

**តារាងទី ៦ : ក៏រិតទឹកប្រាក់អប្បបរិមាសំរាប់ធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ**

ក៏រិតទឹកប្រាក់អប្បបរិមាដើម្បីអនុម័តក្នុងការធ្វើលទ្ធកម្មលើសំភារៈបរិក្ខារមានក្នុងតារាង :

| តំលៃ | អនុម័ត | និតិវិធី |
|---|---|---|
| < $400 | ប្រធានមជ្ឈមណ្ឌលជាតិ, ប្រធាន Sub-component | ទិញដោយផ្ទាល់ |
| $ 400- $80,000 | ប្រធានមជ្ឈមណ្ឌលជាតិ និងមានការចូលរួមក្នុងការវាយតំលៃលើសំណើតំលៃពីតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា | យ៉ាងហោចណាស់មានសំណើសុំតំលៃចំនួន ៣ |
| $80,000 - $100,000 | ប្រធានមជ្ឈមណ្ឌលជាតិ និងមានការចូលរួមក្នុងការវាយតំលៃលើសំណើតំលៃពីតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា | ការដេញថ្លៃក៏រិតជាតិ |
| > $100,000 | ប្រធានមជ្ឈមណ្ឌលជាតិ និងមានការចូលរួមក្នុងការវាយតំលៃលើសំណើតំលៃពីតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា | ការដេញថ្លៃក៏រិតអន្តរជាតិ |

### ៥.១.២. អចនវត្ថុ និង ការចុះបញ្ជីសារពើភ័ណ្ឌ

គ្រប់អចលវត្ថុទាំងអស់ដែលបានទិញដោយមជ្ឈមណ្ឌលជាតិដោយប្រើប្រាស់ថវិការបស់គំរោង ត្រូវបិទផ្លាក និង ចុះចូលក្នុងបញ្ជី "**អចនវត្ថុ និង ការចុះបញ្ជីសារពើភ័ណ្ឌ**" ។ ក្នុងការចុះបញ្ជីតំរូវឱ្យមាននូវពត៌មានមួយចំនួនដូចតទៅ :

- ចំណាត់ថ្នាក់នៃវត្ថុ
- ផ្លាកលេខ
- ការបរិយាយ
- កាលបរិច្ឆេទទិញ
- ចំនួន
- ទីកន្លែង និង ល័ក្ខខ័ណ្ឌរបស់វត្ថុ

អចនវត្ថុដែលទទួលបានថ្មី ត្រូវចុះបញ្ជីសារពើភ័ណ្ឌឱ្យបានឆាប់បំផុត ។ ជាងនេះទៅទៀតការចុះបញ្ជីសារពើភ័ណ្ឌត្រូវធ្វើឡើង ២ ដង ក្នុង ១ ឆ្នាំ មុនពេលសាវនកម្ម ។

## ៥.២. ការធ្វើលទ្ធកម្មលើសេវាកម្ម : បុគ្គល ក្រុមហ៊ុន

### ៥.២.១. ឯកសារយោងសំខាន់ៗ

**កិច្ចសន្យាលើការបំពេញការងារ (APW)**

ចំពោះសេវាកម្មមានតំលៃតិចជាង $900 ដូចជា ការបកប្រែ ការវាយអត្ថបទ ការបញ្ចូលទិន្នន័យ ការថតចម្លង ការផ្គត់ផ្គង់សម្ភារៈ ការថែរក្សា ឬ ការជួសជុល ត្រូវប្រើ កិច្ចសន្យាបំពេញការងារ (APW) ។ គំរូឯកសារទាំងនេះមានក្នុងឧបសម្ព័ន្ធទី ២ ដោយបញ្ជាក់ពី ឈ្មោះ និង អាស័យដ្ឋាន របស់បុគ្គលដែលចុះកិច្ចសន្យា សេវាកម្មដែលផ្តល់ជូន និង ចំនួនថវិកានៅកិច្ចសន្យាបំពេញការងារ ។ កិច្ចសន្យាបំពេញការងារអនុម័ត និង ចុះហត្ថលេខាដោយប្រធានមជ្ឈមណ្ឌលជាតិ ឬ ប្រធាន Sub-component ។

### ៥.២.២. ទីប្រឹក្សាជាបុគ្គល

ចំពោះទីប្រឹក្សាអន្តរជាតិ និង ក្នុងស្រុក ជាបុគ្គល ត្រូវជ្រើសរើសដោយមជ្ឈមណ្ឌលជាតិ និង Sub-component ដោយមានការចូលរួម និងវាយតំលៃដោយតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា ។ និតិវិធីដូចខាងក្រោមនឹងត្រូវអនុវត្ត :

**តារាងទី ៧ : សង្ខេបអំពីដំណើរការជ្រើសរើសទីប្រឹក្សាជាបុគ្គល**

| ជំហាន | សកម្មភាព | អ្នកប្រតិបត្តិ | អនុម័ត |
|---|---|---|---|
| ១ | រៀបចំ Terms of Reference និង លក្ខណៈវិនិច្ឆ័យក្នុងការវាយតំលៃ | មជ្ឈមណ្ឌលជាតិ និង Sub-component | CDC ប្រចាំនៅកម្ពុជា ឬ CDC Atlanta (ទីប្រឹក្សា អន្តរជាតិ) |
| ២ | ការផ្សព្វផ្សាយ<br>• សារពត៌មានក្នុងស្រុក ឬ គេហទំព័ររបស់មជ្ឈមណ្ឌលជាតិ<br>• សារពត៌មានអន្តរជាតិ ឬ គេហទំព័ររបស់មជ្ឈមណ្ឌលជាតិ/ CDC ប្រចាំនៅកម្ពុជា | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៣ | ប្រមូលប្រវិត្តរូប និង រៀបតារាងឈ្មោះ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |

| | | | |
|---|---|---|---|
| ៤ | ចាត់តាំងគណៈកម្មការវាយតំលៃ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៥ | វាយតំលៃប្រវិត្តិរូប និង រៀបតារាងឈ្មោះខ្លី (២-៣ បេក្ខជន) | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និង ចូលរួមដោយតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា |
| ៦ | ការសំភាសន៍ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និង ចូលរួមដោយតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា |
| ៧ | ជ្រើសរើស ចរចារតំលៃពេលចាប់ផ្តើមការងារ ។ល។ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និង ចូលរួមដោយតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា |
| ៨ | ពង្រៀងកិច្ចសន្យា កំណត់តំលៃ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ |
| ៩ | ជ្រើសរើស | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ / CDC Atlanta (ទីប្រឹក្សាអន្តរជាតិ) |

នីតិវិធីនៃការជ្រើសរើសដោយផ្ទាល់ អាចនឹងត្រូវអនុវត្តនៅក្នុងករណីដែលមានបុគ្គលមានសមត្ថភាពតែម្នាក់ដើម្បីអនុវត្តសកម្មភាពណាមួយ ឬ តួទាទីណាមួយជាក់លាក់ ។ ការធ្វើរបាយការណ៍លើការជ្រើសរើសប្រភពតែមួយនោះ ឬ បុគ្គលតែម្នាក់នោះត្រូវរៀបចំដោយបញ្ជាក់ឱ្យបានច្បាស់លើការជ្រើសរើសផ្ទាល់ និង ដាក់ជូនប្រធានមជ្ឈមណ្ឌលជាតិ និង ការិយាល័យ CDC ប្រចាំនៅកម្ពុជា ដើម្បីធ្វើការអនុម័ត ។ គំរូកិច្ចសន្យាដែលត្រូវយកប្រើមានក្នុងឧបសម្ព័ន្ធទី ២ ។

### ៥.២.៣. ការផ្តល់ប្រឹក្សាដោយក្រុមហ៊ុន

និតិវិធីក្នុងការជ្រើសរើសក្រុមហ៊ុនមានបង្ហាញក្នុងតារាងទី ៨ ដូចខាងក្រោម :

**តារាងទី ៨ : សង្ខេបអំពីដំណើរការជ្រើសរើសទីប្រឹក្សាមកពីក្រុមហ៊ុន**

| ជំហាន | សកម្មភាព | អ្នកប្រតិបត្តិ | អនុម័ត |
|---|---|---|---|
| ១ | រៀបចំ Terms of Reference និង លក្ខណៈវិនិច្ឆ័យក្នុងការវាយតំលៃ | មជ្ឈមណ្ឌលជាតិ និង Sub-component | CDC ប្រចាំនៅកម្ពុជា ឬ CDC Atlanta (ទីប្រឹក្សា អន្តរជាតិ) |
| ២ | ផ្សព្វផ្សាយ : សំណើឱ្យដាក់ការចាប់អារម្មណ៍ (Expressions of Interest)<br>• សារពត៌មានក្នុងស្រុក ឬ គេហទំព័ររបស់មជ្ឈមណ្ឌលជាតិ<br>• សារពត៌មានអន្តរជាតិ ឬ គេហទំព័ររបស់មជ្ឈមណ្ឌលជាតិ/ CDC ប្រចាំនៅកម្ពុជា<br>កំណត់ប្រភពផ្គត់ផ្គង់មួយ (identify sole source) | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ |
| ៣ | រៀបតារាងឈ្មោះ (១-៥បេក្ខជន) | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៤ | ជាត់តាំងគណៈកម្មការវាយតំលៃ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ |
| ៥ | វាយតំលៃ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និង ចូលរួមដោយតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា |

| | | | |
|---|---|---|---|
| ៦ | ជ្រើសរើស ចរចារតំលៃ ពេលចាប់ផ្តើមការងារ | មជ្ឍមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឍមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និងចូលរួមដោយតំណាងការិយាល័យ CDC ប្រចាំនៅកម្ពុជា |
| ៧ | ពង្រៀងកិច្ចសន្យា កំណត់តំលៃ | មជ្ឍមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឍមណ្ឌលជាតិ |
| ៨ | ការជ្រើសរើស | មជ្ឍមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឍមណ្ឌលជាតិ / CDC Atlanta (ក្រុមហ៊ុនអន្តរជាតិ) |

## ៥.៣. ការធ្វើលទ្ធកម្មលើការងារសំណង់

ចំពោះការជួសជុល ឬការសាងសង់ចំណាយតិចជាង $25,000 គេត្រូវអនុវត្តតាមនិតិវិធីដូចតទៅនេះ :

១. ការជួសជុល ឬ សាងសង់ ត្រូវតែមាននៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ និងប្រចាំឆមាស

២. បង្កើតក្រុមការងារវាយតំលៃ ដែលមានសមាសភាព : វិស្វករ ១ រូប មកពី ក្រសួងសុខាភិបាល ឬជួលពីខាងក្រៅ មន្ត្រីធ្វើការងារលទ្ធកម្មនៅមជ្ឍមណ្ឌជាតិ/វិទ្យាស្ថាន និង តំណាងផ្នែកជំនាញពាក់ព័ន្ធនៃមជ្ឍមណ្ឌល និង Sub-component ។

៣. ក្រុមការងារវាយតំលៃ ត្រូវចុះពិនិត្យកន្លែងដែលស្នើសាងសង់ ហើយសរសេររបាយការណ៍នៃការវាយតំលៃនោះដោយត្រូវមានការយល់ព្រមពីសមាជិកគ្រប់ៗគ្នា ហើយបន្ទាប់មកផ្ញើរបាយការណ៍នោះជូនប្រធានមជ្ឍមណ្ឌជាតិ/វិទ្យាស្ថាន។ របាយការណ៍ត្រូវរៀបរាប់អំពីហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ប្រសិនជាមាន លើកផែនការសំរាប់ជួសជុល ឬ សាងសង់ និង ធ្វើ Bill of Quantities ដោយផ្អែកទៅលើផែនការ ។ សំណើនេះត្រូវមានការឯកភាពពី Sub-component ។

៤. ត្រូវមានការប៉ាន់ស្មានតំលៃ (quotations) យ៉ាងតិចចំនួន ៣ មកពីក្រុមហ៊ុនចំនួន ៣ ផ្សេងគ្នា (ឧបសម្ព័ន្ធទី ៣) ។

៥. ការប៉ាន់ស្មានតំលៃនឹងត្រូវធ្វើការវាយតំលៃ និងការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនដែលជ្រើសរើសយក (contract awarded) ។ លក្ខ័ខ័ណ្ឌនៃកិច្ចសន្យារួមទាំងការបង់ថ្លៃ ២០% នៃតំលៃកិច្ចសន្យាក្នុងពេលចុះកិច្ចសន្យា ហើយត្រូវបង់ថ្លៃ

៧០% នៅក្នុងកំឡុងរយៈពេលបំពេញការងារ និង បង់ថ្លៃចុងក្រោយ ១០% នៅពេលដែលទទួលបាននូវលិខិតញ្ជាក់ថាការងារត្រូវបានបំពេញចប់សព្វគ្រប់ពីមជ្ឈមណ្ឌជាតិ ឬ Sub-component ។

៦. មន្ទីរសុខាភិបាលខេត្ត/ការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិ នឹងចុះត្រួតពិនិត្យការងារសាងសង់ និងក្រុមវាយតំលៃនឹងចុះពិនិត្យមើលពេលការសាងសង់ត្រូវបានបញ្ចប់ ។ នៅក្នុងរបាយការណ៍ មជ្ឈមណ្ឌលជាតិ និង Sub-component នឹងផ្តល់ជូនលិខិតបញ្ជាក់ពីការបញ្ចប់ការងារ ។

៧. ការបង់ថ្លៃចុងក្រោយ ១០% ជូនដល់អ្នកសាងសង់ គឺក្រោយពេល ៦ ខែ ក្រោយពីបញ្ចប់ការងារជួសជុល និងក្រោយពេល ១២ ខែ ចំពោះការសាងសង់សំណង់ថ្មី ។

**តារាងទី ៩ : សង្ខេបអំពីដំណាក់កាលនៃការធ្វើលទ្ធកម្មលើការងារជួសជុលខ្នាតតូច**

| ជំហាន | សកម្មភាព | អ្នកប្រតិបត្តិ | អនុម័ត |
|---|---|---|---|
| ១ | ការរៀបចំសំណើ ដូចមានចែងក្នុងផែនការ ប្រចាំឆ្នាំ និងប្រចាំឆមាស | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវ សុខភាពសាធារណៈ |
| ២ | ការតែងតាំងក្រុមវាយតំលៃ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៣ | ការសិក្សាវាយតំលៃ និង របាយការណ៍ វាយតំលៃ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៤ | សំណើឱ្យដាក់ quotation | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៥ | ការវាយតំលៃ និង contract award | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវ សុខភាពសាធារណៈ និងចូលរួមដោយតំណាង ការិយាល័យ CDC ប្រចាំនៅកម្ពុជា (តំលៃលើសពី US$25,000.00) |
| ៦ | ការត្រួតពិនិត្យការសាងសង់ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |

| | | | |
|---|---|---|---|
| ៧ | លិខិតបញ្ជាក់ពីការបញ្ចប់ការងារ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ |
| ៨ | ការបង់ថ្លៃចុងក្រោយ | មជ្ឈមណ្ឌលជាតិ និង Sub-component | មជ្ឈមណ្ឌលជាតិ និង Sub-component |

### ៥.៤. ការវាយតំលៃលើការងារលទ្ធកម្ម

ការវាយតំលៃលើការសំណើតំលៃ (quotations) ការដេញថ្លៃ (bids) និង គំរោង (proposals) ។ល។ នឹងត្រូវអនុវត្តដោយគណៈកម្មការវាយតំលៃលទ្ធកម្ម (ឬគណៈកម្មការជ្រើសរើសនៅក្នុងករណីជ្រើសរើសទីប្រឹក្សា) ។ សមាជិករបស់គណៈកម្មការ នឹងត្រូវតែងតាំងដោយមជ្ឈមណ្ឌលជាតិ/វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ។

### ៥.៥ ការធានារ៉ាប់រង

បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជា មិនបានផ្តល់សេវាធានារ៉ាប់រងជូនមន្ត្រីរាជការ ការធ្វើដំណើរ ឬរថយន្ត និងសំភារៈទេ។ ក្នុងករណីចាំបាច់ មន្ត្រីរាជការ ការធ្វើដំណើរ រថយន្ត និង សំភារៈទាំងនោះតំរូវឱ្យមានការធានារ៉ាប់រងដោយប្រើថវិការបស់គំរោងពាក់ព័ន្ធ ។ ការធ្វើលទ្ធកម្មលើសេវាធានារ៉ាប់រងនឹងត្រូវអនុវត្តតាមនិតិវិធីដូចការធ្វើលទ្ធកម្មដែលបានចែងនៅក្នុងឯកសារនេះ ។

## ៦ . ការកំណត់អត្រាប្រាក់ឧបត្ថម្ភសំរាប់ធ្វើដំណើរក្នុងប្រទេស ការចុះអភិបាល និង ប្រាក់សំរាប់លើកទឹកចិត្តក្នុងការអនុវត្តន៍ការងារ

**តារាងទី ១០ : ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសំរាប់មន្ត្រីរដ្ឋាភិបាល ក្នុងការធ្វើចុះបំពេញបេសកម្មក្នុងប្រទេស**

| ទីកន្លែង | អត្រាជា US$ | |
|---|---|---|
| | ស្នាក់នៅពេលយប់ | មួយថ្ងៃពេញ តែមិនស្នាក់នៅពេលយប់ |
| ពីខេត្ត/ក្រុង មកភ្នំពេញ | 25 | 5 |
| ពីភ្នំពេញ ទៅកាន់ទីរួមខេត្ត-ក្រុងទាំងអស់ | 20 | 5 |
| ពីខេត្ត/ក្រុង ទៅខេត្ត/ក្រុង | 20 | 5 |
| ពីស្រុកទៅ ខេត្ត/ក្រុង | 15 | 5 |
| ពីខេត្ត/ក្រុង ទៅស្រុក ឬ ភូមិ | 15 | 5 |

**តារាងទី ១១ : ប្រាក់ឧបត្ថម្ភ សិក្ខាកាមចូលរួមក្នុងការបណ្តុះបណ្តាល ឬ សិក្ខាសាលា**

| ប្រាក់ឧបត្ថម្ភ | អត្រាជា US$ |
|---|---|
| អ្នកសំរបសំរួលវគ្គ (ប្រសិនជាគ្មានប្រាក់ឧបត្ថម្ភ) | 12.5 ក្នុង ១ ថ្ងៃ |
| សិក្ខាកាម (ប្រសិនជាគ្មានប្រាក់ឧបត្ថម្ភ) | 5 ក្នុង ១ ថ្ងៃ |

| | |
|---|---|
| សំភារៈសិក្សា ( គីរីតថេរ ) | 2 ក្នុង ១ នាក់ |
| អាហារសំរន់ ( គីរីតថេរ ) | 1 ក្នុង ១ នាក់ |

សំគាល់ : ប្រាក់ឧបត្ថម្ភសំរាប់សំភារៈសិក្សា ឬអាហារសំរន់សំរាប់សិក្ខាកាម និងវគ្គបណ្តុះបណ្តាល គឺ មិនប្រគល់ជូនសិក្ខាកាមជាសាច់ប្រាក់នោះទេ។ ប៉ុន្តែវាជាពតិមានសំរាប់គណនេយ្យករ ឬអ្នករៀបចំធ្វើការគណនាប៉ាន់ស្មានថ្លៃចំណាយសំរាប់វគ្គបណ្តុះបណ្តាល ។

**តារាងទី ១២ : អត្រាប្រាក់ឧបត្ថម្ភនៅពេលបំពេញការងារ**

| ***ការងារ*** | ***អត្រា*** **(US$) ក្នុង ១ ទំព័រ** |
|---|---|
| បកប្រែអត្ថបទ | 5 |
| កែសំរួលអត្ថបទ | 3 |
| វាយអត្ថបទ | 2 |
| ថតចំលងឯកសារ | 0.02 |

ចំពោះសេវាកម្មវាយអត្ថបទ បកប្រែ និងកែសំរួលអត្ថបទ ដែលមានតំលៃតិចជាង US$900 អាចធ្វើកិច្ចសន្យាផ្ទាល់បាន ។

ទំហំទំព័រសំរាប់បកប្រែត្រូវមានលក្ខណៈដូចខាងក្រោមនេះ :

**អត្ថបទត្រូវមានទំហំអក្សរ :**

- ភាសាអង់គ្លេស
- មានពី ៣០០ ទៅ ៥០០ ពាក្យជាមធ្យមក្នុង ១ ទំព័រ ( ៥ តួអក្សរក្នុង ១ពាក្យ)
- ទំហំអក្សរ ១១ (Arial)
- ទំហំអក្សរ ១២ (Time New Roman)
- រឹមទំព័រ 1 inch ( ខាងលើ, ខាងក្រោម, ខាងឆ្វេង និង ខាងស្តាំ)

**ទំហំរូបភាព និង** graphic

រូបភាព/ graphic មានតិចជាង ៥០% នៃទំព័រប្រកាស នឹងប្រើអត្រាខាងលើ

រូបភាព/ graphic មានលើសពី ៥០% នៃទំព័រប្រកាស នឹងគិតអត្រា $2 ក្នុង ១ទំព័រ និងមិនមានរួមបញ្ចូលថ្លៃវាយអត្ថបទ គូររូបភាព និងបកប្រែទេ ។

## ៧ ‐ សោហ៊ុយសំរាប់ការធ្វើដំណើរក្រៅប្រទេស

សំរាប់ការធ្វើដំណើរក្រៅប្រទេស អត្រាសោហ៊ុយសំរាប់ស្នាក់នៅ និងសោហ៊ុយប្រចាំថ្ងៃរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងត្រូវយកមកប្រើប្រាស់ ។ ការធ្វើដំណើរក្រៅប្រទេសត្រូវមានការឯកភាពប្រធានមជ្ឈមណ្ឌលជាតិ និង ប្រធានការិយាល័យ CDC ប្រចាំនៅកម្ពុជា ជាមុនសិន ។

ការធ្វើដំណើរក្រៅប្រទេស មិនតំរូវអោយមានប្រើសំណើតំលៃ ៣ក្រុមហ៊ុនទេ ។

អ្នកធ្វើដំណើរត្រូវទទួលខុសត្រូវក្នុងការស្វែងរកការឯកភាពលើការចំណាយចាំបាច់ផ្សេងៗសំរាប់ធ្វើដំណើរ ដូចជា ថ្លៃចូលរួមសន្និសិទ ជួលរថយន្ត ។ល។ មុននឹងទទួលការចំណាយដែលផ្តល់អោយដោយមជ្ឈមណ្ឌលជាតិ ។

អត្រាថេរសំរាប់ចំណាយប្រចាំថ្ងៃ គឺ $127 ក្នុង ១ថ្ងៃ ត្រូវបានអនុញ្ញាតអោយសំរាប់ការធ្វើដំណើរទៅទីក្រុងបាងកក ប្រទេសថៃ ។

លើកលែងការចំណាយថេរប្រចាំថ្ងៃ ឯកសារបញ្ជាក់ដើម្បីទូទាត់តំរូវអោយមានបង្កាន់ដៃទទួលប្រាក់សំរាប់សំបុត្រយន្តហោះ សណ្ឋាគារ ធ្វើទិដ្ឋាការ ចុះឈ្មោះចូលរួមសន្និសិទ និងថ្លៃរថយន្តឈ្នួល ។

---------------------------------------

**វេជ្ជ. មាន ឈីវុន**

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និង កាមរោគ

ថ្ងៃទី ខែ ឆ្នាំ ២០០....

---------------------------------------

**វេជ្ជ. Bradley S. Hersh**

ប្រធានការិយាល័យ CDC ប្រចាំនៅកម្ពុជា

ថ្ងៃទី ខែ ឆ្នាំ ២០០....

**ឧបសម្ព័ន្ធទី ១ : សេចក្តីសង្ខេបអំពីដំណើរការនៃការធ្វើលទ្ធកម្ម**

១.១. ការសំរួលលើដំណើរការធ្វើលទ្ធកម្មសំភារៈបរិក្ខារ

១.២. សំណើតំលៃលើសំភារៈបរិក្ខារ (Request for Quotations)

១.៣. កិច្ចសន្យា

## ១.១. ការសំរួលលើដំណើរការធ្វើលទ្ធកម្មលើសំភារៈបរិក្ខារ

***ការទិញផ្ទាល់*** *(Direct Purchase):*

ការទិញផ្ទាល់ត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចតទៅ :

១. រៀបចំលិខិតសុំទិញ (Purchase Request) មួយដែលមានបញ្ជាក់នូវបរិមាណដែលត្រូវការ និងត្រូវរៀបចំលំអិតលក្ខណ:បច្ចេកទេស ។

២. អ្នកផ្គត់ផ្គង់សំខាន់ៗនឹងត្រូវបានអញ្ជើញអោយដាក់សំណើតំលៃ និង លំអិតលក្ខណ:បច្ចេកទេសរបស់ទំនិញដែលត្រូវទិញ (សូមមើលសំណើដាក់តំលៃខាងក្រោម) ។ អ្នកផ្គត់ផ្គង់សំខាន់ៗអាចត្រូវបានកំណត់ដោយអ្នកស្នើសុំទិញ ឬ មន្ត្រីលទ្ធកម្ម ។ អ្នកផ្គត់ផ្គង់ទាំងអស់ត្រូវបានអនុញ្ញាតយ៉ាងតិចបំផុតចំនួន ៥ ថ្ងៃ ដើម្បីដាក់សំណើតំលៃមកមជ្ឈមណ្ឌលជាតិវិញ ។ យ៉ាងតិចណាស់ត្រូវមានសំណើតំលៃមកពី ៣ ក្រុមហ៊ុន ។

៣. បន្ទាប់ពីកាលបរិច្ឆេទដាក់សំណើតំលៃផុតកំណត់ គណ:កម្មការវាយតំលៃដែលបង្កើតឡើងដោយមជ្ឈមណ្ឌលជាតិនឹងបើកសំណើតំលៃ ហើយជ្រើសរើសយកអ្នកផ្គត់ផ្គង់មួយ ។ គណ:កម្មការវាយតំលៃត្រូវមានសមាជិកតិចជាង ៣ នាក់ ។

៤. កំណត់ហេតុកិច្ចប្រជុំស្តីពីការពិភាក្សា និងការសំរេចចិត្តរបស់គណ:កម្មការវាយតំលៃត្រូវតែកត់ត្រាទុក ។

ក្នុងករណីទទួលបានសំណើតំលៃតិចជាង ៣ ក្រុមហ៊ុន ទោះបីជាមានការអញ្ជើញច្រើនក៏ដោយ ប្រធានមជ្ឈមណ្ឌលជាតិនឹងធ្វើការសំរេច :

- ចុះកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់តែមួយក្នុងរយ:ពេលមិនលើសពី ១ឆ្នាំ ឬ
- ចុះកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ដែលបានដាក់សំណើតំលៃ ប្រសិនបើគណ:កម្មការវាយតំលៃអាចទទួលយកបាន ។

### ប្រភពស្វែងរកសំណើតំលៃ

ការស្វែងរកសំណើតំលៃអាចធ្វើឡើងតាមរយ:អ្នកផ្គត់ផ្គង់ទាំងអស់ (បើអាចធ្វើបាន) ។ នេះបញ្ជាក់ឱ្យឃើញថា រាល់អ្នកផ្គត់ផ្គង់ទាំងអស់ត្រូវបានពិចារណា ។ អ្នកផ្គត់ផ្គង់ល្អៗ ជាទូទៅនឹងត្រូវជ្រើសរើសតាមរយ:

- បទពិសោធន៏ក្នុងផ្គត់ផ្គង់អោយមជ្ឈមណ្ឌលជាតិកន្លងមក
- ដៃគូការងារដែលកំពុងអនុវត្តកម្មវិធីប្រហាក់ប្រហែលនឹងមជ្ឈមណ្ឌលជាតិ
- សៀវភៅទំព័រលឿង ព្រឹត្តិប័ត្រពតិមាន កាសែត

### ការទិញឡើងវិញ

ប្រសិនបើសំណើសុំទិញបញ្ជាក់នូវទំនិញ ឬ សេវាកម្មដែលមានលក្ខណ:ដូច ឬ ស្រដៀងទៅនឹងទំនិញដែលបានទិញកន្លងរួចមកហើយក្នុងរយ:ពេល ១២ខែ តាមរយ:ការដេញថ្លៃ សំណើសុំទិញនោះអាចត្រូវឯកភាពដោយប្រធានមជ្ឈមណ្ឌល

